អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / APR / 2009
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 03 / APR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier:

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**

**Bureau des Co-juges d'instruction**

**សំណុំរឿងលេខ: 002/19-09-2007-ECCC-OCIJ**

**ចំពោះមុខ:** ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

**កាលបរិច្ឆេទ:** ០៣ មេសា ២០០៩

**ភាសាដើម:** ខ្មែរ/បារាំង

**ប្រភេទឯកសារ:** សាធារណៈ

---

# ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ

---

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT

**ជនត្រូវចោទ**

នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ចាន់ឌី
ឡោ ជុនធី
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Philippe CANONNE
Elizabeth RABESANDRATANA
Pierre-Olivier SUR
Mahdev MOHAN
Olivier BAHOUGNE
David Blackman
SILKE Studzinsky

**សហមេធាវីការពារក្តី**

សុន អរុណ
Michiel Pestman
អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana Ellis
ស សូវ៉ាន
Jacques Vergès

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** សហចៅក្រមស៊ើបអង្កេតនៃអង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក.”)

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (“ច្បាប់ស្តីពី អ.វ.ត.ក.”)

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **នួន ជា** និង **ជនផ្សេងទៀត** ទាក់ទងនឹងបទចោទប្រកាន់អំពី **បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក.

បានឃើញសំណើសុំបំពេញកិច្ចស៊ើបសួរទី ១១ (“សំណើសុំ”) ដាក់ដោយក្រុមមេធាវីការពារក្តី នួន ជា (“ក្រុមមេធាវីការពារក្តី”) ធ្វើឡើងនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ (D158)

បានឃើញសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី អៀង សារី (D158/2) របស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ (D158/3) និង ខៀវ សំផន ដែលធ្វើឡើងនៅថ្ងៃទី ២៧ និង ៣០ មីនា និង ០៣ មេសា ២០០៩។

**<u>ការរំលឹកឡើងវិញអំពីនីតិវិធី និងអង្គហេតុរបស់នីតិ</u>**

១. តាមរយៈសំណើសុំចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ និងដោយផ្អែកលើអត្ថបទសារព័ត៌មានជាច្រើន ដែលបានបរិយាយអំពីការចោទប្រកាន់អំពីអំពើពុករលួយនៅក្នុង អ.វ.ត.ក. ក្រុមមេធាវីការពារក្តី នួន ជា បានស្នើឲ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរលើអង្គហេតុទាំងនេះ។

២. បន្ទាប់ពីបានលើកឡើងអំពី កត្តាផ្សេងៗដែលគាំទ្រដល់ការសង្ស័យរបស់ពួកគេអំពីបញ្ហាពុករលួយនៅក្នុង អ.វ.ត.ក. (ផ្នែក ២-ក) អំពី *"ប្រតិកម្ម និងការបរិយាយជាផ្លូវការនានា"* (ផ្នែក ២-ខ) និងជាចុងក្រោយអំពី *"កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមមេធាវីការពារក្ដី"* ក្រុមមេធាវីការពារក្ដី នួន ជា បានបញ្ជាក់ថា សំណើសុំរបស់ពួកគេមានកម្មវត្ថុក្នុងការ *"វាយតម្លៃថាតើ អ.វ.ត.ក. អាចនឹងមានលទ្ធភាពក្នុងផ្ដល់នូវយុត្តិធម៌ ស្របតាមបទដ្ឋានសមធម៌អន្តរជាតិ ឬទេ"* និងដែលពួកគេធ្វើដូច្នេះ ដោយហេតុថាពួកគេធ្វើដើម្បីឱ្យមានការគោរពគោលការណ៍តម្លាភាព និងដោយសារថា *"ទាំងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាខ្វះឆន្ទៈក្នុងការជួយដល់ការស៊ើបអង្កេតលើបញ្ហានេះ"*។

៣. ក្នុងន័យនេះ ក្រុមមេធាវីការពារក្ដីបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត *"ធ្វើការប្រមូលគ្រប់ព័ត៌មាន ដែលមានប្រយោជន៍ដល់ការបង្ហាញការពិតអំពីតុលាការនេះ"* និងជាពិសេស *"រកឱ្យឃើញអំពើពុករលួយនៅក្នុងតុលាការ"*។

៤. ក្នុងន័យនេះ ក្រុមមេធាវីការពារក្ដីបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតស្វែងរកពីអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាលកម្ពុជា និង/ឬ អង្គការនានា ឬ គ្រប់បុគ្គលទាំងអស់ នូវ៖

ក) លទ្ធផលនៃការស៊ើបអង្កេតធ្វើឡើងនៅក្នុងខែ មិថុនា ឆ្នាំ ២០០៨ ដោយការិយាល័យ ភ្នាក់ងារត្រួតពិនិត្យផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិ (អក្សរកាត់បារាំង BSCI) លើបញ្ហានេះ
ខ) រាល់លិខិតឆ្លើយឆ្លងទាំងអស់រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការស៊ើបអង្កេតរបស់ BSCI
គ) រាល់ព័ត៌មានផ្សេងទៀត ដែលនាំឱ្យការសង្ស័យអំពីអត្ថិភាពនៃប្រព័ន្ធអំពើពុករលួយនៅក្នុង អ.វ.ត.ក.

ហើយសូមឱ្យសហចៅក្រមស៊ើបអង្កេត ផ្ដល់ព័ត៌មានទាំងអស់នោះឱ្យដល់ក្រុមមេធាវីការពារក្ដី និងភាគីផ្សេងទៀតដែលពាក់ព័ន្ធ ក្នុងរយៈពេលឆាប់បំផុតតាមដែលអាចធ្វើបាន។ ជាងនេះទៅទៀត ក្រុមមេធាវីការពារក្ដីបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបអង្កេតរដ្ឋបាល ទាក់ទងនឹងការចោទប្រកាន់អំពីអំពើពុករលួយនៅក្នុងស្ថាប័នតុលាការនេះ។



ECCC * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៥. នៅក្នុងសារណាធ្វើឡើងនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ ក្រុមមេធាវីការពារក្តី អៀង សារី បាន បង្ហាញអំពីឆន្ទះរបស់ខ្លួនក្នុងការចូលរួមជាមួយសំណើសុំនេះដែរ។

៦. នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៩ ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ បានជូនដំណឹងថា ពួកគេក៏ គាំទ្រដល់ដំណើរការកិច្ចការរបស់ក្រុមមេធាវីការពារក្តី នួន ជា ផងដែរ។

៧. នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៩ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានជូនដំណឹងថា ពួកគេក៏ គាំទ្រដល់ដំណើរការកិច្ចការរបស់ក្រុមមេធាវីការពារក្តី នួន ជា ផងដែរ។

**<u>សំអាងហេតុនៃសេចក្តីសម្រេច</u>**

៨. អំណាចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការ *"បំពេញកិច្ចស៊ើបសួរ ដែលខ្លួនយល់ថាមាន ប្រយោជន៍ដល់ការបង្ហាញការពិត"* ត្រូវអនុវត្តនៅក្នុងក្របខណ្ឌសមត្ថកិច្ចរបស់ខ្លួន ដែលកំណត់ដោយ មាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. *"ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើ ច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់ អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបាន ប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ៦ មករា ១៩៧៩"*។

៩. ការកត់សម្គាល់ខាងលើនេះ ត្រូវបានបន្ថែមដោយបញ្ញត្តិនៃវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង និងដែល ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ព្រោះសហចៅក្រមស៊ើបអង្កេតអាចបើកិច្ចស៊ើបសួរតែទៅលើ អង្គហេតុ ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿង ឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ។

១០. ក្នុងន័យនេះ អំណាចនេះមិនក្តោបទៅដល់សមត្ថកិច្ចក្នុងការបង្ហាញការពិត *"អំពីតុលាការនេះ"* ដូច តាមការចង់បានរបស់ក្រុមមេធាវីការពារក្តីនោះទេ វាគឺបញ្ហា ដែលមិនពាក់ព័ន្ធទាល់តែសោះជាមួយ នឹងអង្គហេតុ ដែលជាកម្មវត្ថុនៃកិច្ចស៊ើបសួរបច្ចុប្បន្ន។ នៅថ្ងៃទី ១៤ មករា ឆ្នាំ ២០០៩ សហចៅក្រម ស៊ើបអង្កេតបានបដិសេធមិនបញ្ចូលទៅក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧ នូវបណ្តឹង ដែល

00294897



ដាក់ដោយក្រុមមេធាវីការពារក្ដី នួន ជា ចំពោះមុខព្រះរាជអាជ្ញានៃតុលាការក្រុងភ្នំពេញ ធ្វើឡើងនៅថ្ងៃទី ០៨ មករា ២០០៩ នោះទេ ដោយហេតុថា បណ្ដឹងនោះមិនពាក់ព័ន្ធនឹងអង្គហេតុ ដែលជាកម្មវត្ថុនៃកិច្ចស៊ើបសួរ។ (D124/1)

១១. ដោយយោងទៅលើកត្តាទាំងអស់នេះ និងដោយមិនគិតអំពីភាពសមស្របសមហេតុផលនៃការចោទប្រកាន់ ដែលបានលើកឡើងនៅក្នុងសំណើសុំ បញ្ហាគឺថា ការការឆ្លើយតបជាវិជ្ជមានចំពោះសំណើសុំបែបនោះ វាគឺជាការប្រើប្រាស់អំណាចក្នុងផ្លូវខុស ព្រោះអង្គហេតុទាំងនោះមិនឋិតនៅក្នុងសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមច្បាប់ស្ដីបង្កើត អ.វ.ត.ក. នោះទេ។ គ្មានហេតុផលណាមួយ ដែលថាមានការមិនគោរពគោលការណ៍គ្រឹះនៃនីតិរដ្ឋនោះទេ ដែលគោលការណ៍នីតិរដ្ឋនេះ ក៏ជានិយាយអំពីការផ្ដល់អំណាចទៅឲ្យអាជ្ញាធរតុលាកាដែរ គឺ៖ ការដាក់ឲ្យអង្គចៅក្រមឋិតនៅក្រោមច្បាប់។

១២. ពិតណាស់ សហចៅក្រមស៊ើបអង្កេតត្រូវធានាថា គ្រប់ចំណុចនៃ នីតិវិធីដែលកំពុងដំណើរការក្នុងពេលបច្ចុប្បន្ន នៅក្នុង អ.វ.ត.ក. មិនត្រូវបានគេមិនគោរព ជាពិសេសចំពោះរឿង ដែលថា គ្រប់ទង្វើ ដែលជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះទាំងអស់ត្រូវបាន *"ដាក់ទណ្ឌកម្ម និងបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច"* ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ ផ្ទុយទៅវិញ គ្មានអ្វីដែលអាចបញ្ជាក់បានអំពីអត្ថិភាពនៃទង្វើបែបនេះទេ សំណើសុំនោះគ្រាន់តែបានលើកឡើងអំពី
ការប្រមើលមើលឃើញអំពីផលវិបាកដ៏អាក្រក់ជាយថាហេតុណាមួយ ប្រសិនបើមានអំពើពុករលួយគ្រប់រូបភាពកើតឡើង ចំពោះដំណើរការនៃនីតិវិធីតុលាការតែប៉ុណ្ណោះ។

១៣. ជាចុងបញ្ចប់ សំណើសុំឲ្យមានការស៊ើបអង្កេតរដ្ឋបាលលើបញ្ហានេះពីសំណាក់សហចៅក្រមស៊ើបអង្កេត គឺជារឿងឥតប្រយោជន៍ ព្រោះថាទាំងអាជ្ញាធរកម្ពុជា និងអង្គការសហប្រជាជាតិជាអ្នកមានសមត្ថកិច្ចលើបញ្ហានេះ ហើយមានគ្រប់ព័ត៌មានទាំងអស់ ដែលមានលើកឡើងនៅក្នុងសំណើសុំ។ ជាមួយគ្នានេះដែរ ដីកាសម្រេចនេះនឹងត្រូវបានថតចម្លង និងបញ្ជូនទៅអាជ្ញាធរទាំងនោះ ដើម្បីជាព័ត៌មានផងដែរ។



C.E.T.C. * E.C.C.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ហេតុដូច្នេះ

- **សម្រេចថា** សហចៅក្រមស៊ើបអង្កេតគ្មានសមត្ថកិច្ចក្នុងការបំពេញកិច្ចស៊ើបសួរ ដែលបានស្នើសុំមកនេះ។
- **បដិសេធ** មិនធ្វើការស្នើសុំឲ្យធ្វើការស៊ើបអង្កេតរដ្ឋបាល។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៩

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-Juges d'instruction**

MARCEL Lemonde

យូ ប៊ុនឡេង